The speech of Chea Sim in the inauguration of Buddhist school.

# សុន្ទរកថា

## សម្តេច ជា ស៊ីម ប្រធានរដ្ឋសភា និងជាព្រះរាជតំណាងនៃព្រះមហាក្សត្រ
## ក្នុងពិធីសម្ពោធអាគារពុទ្ធសាសនបណ្ឌិត្យ
## នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៨ May 28, 1998

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និង ព្រះថេរានុត្ថេរគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សូមធ្វើអភិវន្ទនកិច្ចចំពោះ ព្រះតេជគុណ មីណាមី គូសី ជាប្រធាន និងព្រះតេជគុណទាំងឡាយ ជាសមាជិកនៃគណៈប្រតិភូ ឋិស្សូ គូស៊ី-កៃ ជាទីគោរព
- សូមសំដែងអភិវន្ទនកិច្ច ចំពោះព្រះតេជគុណ ហ៊ៀនដូ ម៉ាកស៊ូណាហ្គា ជាប្រធានសមាគមស្ម័គ្រចិត្ត សូតូស៊ូ ជាទីគោរព
- សូមគោរព ឯកឧត្តម ឯកអគ្គរាជទូត រដ្ឋទូត និងតំណាងស្ថានទូតនានា នៃបណ្តាប្រទេសជាមិត្ត ជាទីមេត្រី
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី
- អស់លោក លោកស្រី ជាពុទ្ធបរិស័ទ ព្រមទាំងបងប្អូនជនរួមជាតិ ជាទីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសដ៏ឱឡារិកថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានមហាកិត្តិយសក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសីជាទីគោរពសក្ការៈ ដែលទ្រង់បានចាត់តាំង ខ្ញុំព្រះករុណាខ្ញុំ ជាព្រះរាជតំណាងផ្លូវការរបស់ព្រះអង្គ មកចូលរួមជាធិបតី ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវអាគារថ្មីរបស់ពុទ្ធសាសនបណ្ឌិត្យ ដែលកំពុងប្រព្រឹត្តទៅនាពេលនេះ ។ ខ្ញុំព្រះករុណាខ្ញុំ សូមពាំនាំនូវព្រះរាជបន្ទូលផ្តាំសាកសួរសុខទុក្ខរបស់ព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសីជាទីគោរពសក្ការៈ ដែលទ្រង់សព្វព្រះទ័យប្រទានផ្ញើជូន កូន-ចៅ-ចៅទួតរបស់ព្រះអង្គដែលមានវត្តមាននៅក្នុងទីនេះ នូវព្រះរាជបូទ័យនឹងរលឹកដ៏ស្មោះស្ម័គ្របំផុតអំពីព្រះអង្គជានិច្ច និងសូមកូន-ចៅ-ចៅទួត របស់ព្រះអង្គបានប្រកបដោយសុភមង្គល និងសុខសន្តិភាពអស់កាលជានិរន្តរ៍ ។

ខ្ញុំព្រះករុណាខ្ញុំ បានតាមដានស្តាប់ដោយយកចិត្តទុកដាក់នូវសុន្ទរកថារបស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ព្រមទាំងបន្ទូលដ៏មានអត្ថន័យដ៏ខ្ពង់ខ្ពស់របស់ព្រះតេជគុណ យូស៊ីណូប៊ុ មីណាមី ប្រធានមូលនិធិ ដើម្បីសន្តិភាពនៃអង្គការរីស្សូកូស៊ី-កៃ ។ ជាការពិតណាស់ ពុទ្ធសាសនបណ្ឌិត្យ គឺជាស្ថាប័នជាតិដ៏ចំណាស់មួយ ក្នុងចំណោមស្ថាប័នជាតិចាស់ទុំ ឯទៀតៗ ដែលបានដើរតួយ៉ាងសកម្មក្នុងការសិក្សា និងស្រាវជ្រាវ ពុទ្ធសាសនាថេរវាទ អក្សរសាស្ត្រ ប្រពៃណី និងទំនៀមទម្លាប់ជាតិ ហើយបានបោះពុម្ពផ្សព្វផ្សាយទូលំទូលាយ និងបានរក្សាទុកនូវស្នាដៃ ស្រាវជ្រាវទាំងនោះ មួយអន្លើដោយក្បួនតម្រា គម្ពីរ ដីកា ជាភាសាបាលី និងជាភាសានៃប្រទេសកាន់ ពុទ្ធសាសនាដទៃទៀត និងភាសាលោកខាងលិចខ្លះ ទៀតផង ។ ក្រៅពីនេះ នៅមានឯកសារមួយចំនួនធំ ស្តីពីប្រធានបទជាច្រើន ដែលអ្នកប្រាជ្ញជាតិយើងជាច្រើនជំនាន់បន្តបន្ទាប់ បានស្រាវជ្រាវចងក្រងតម្កល់ទុកជាឯកសារ មិនទាន់បានបោះពុម្ព ដែលសុទ្ធសឹងជាឯកសារដើម មានតម្លៃខ្ពស់ ។ មានអ្នកប្រាជ្ញបរទេសជាច្រើន បានទទួលស្គាល់បណ្ណាល័យរបស់ពុទ្ធ សាសនបណ្ឌិត្យថាជាបណ្ណាល័យវិទ្យាសាស្ត្រតែមួយគត់របស់ប្រទេស ដែលបើកទ្វារជូនសាធារណជន អានជារៀងរាល់ថ្ងៃ និងផ្ទុកដោយឯកសារកម្រៗ និងមានតម្លៃខ្ពស់សម្រាប់ឱ្យអ្នកស្រាវជ្រាវខ្មែរ និងបរទេស ព្រះសង្ឃ និងគ្រហស្ថ ព្រមទាំងនិស្សិត សិក្សាស្វែងយល់វប្បធម៌ និងអរិយធម៌បូព៌ាប្រទេស ហើយជាពិសេសវប្បធម៌ និងអរិយធម៌ខ្មែរ ។

មានភស្តុតាង និងសក្ខីភាពច្រើនណាស់ បានបញ្ជាក់នូវតួនាទីដ៏សកម្មរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងបេសកកម្មបំរើសង្គមជាតិដូចបានរៀបរាប់ដោយសង្ខេបខាងលើ ។ ពុទ្ធសាសនបណ្ឌិត្យបានរួមចំណែកជាមួយស្ថាប័នសិក្សាដទៃទៀត ដូចជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជជាដើម ក្នុងការបណ្តុះបណ្តាល និងផ្តល់ចំណេះដឹងដល់ភិក្ខុសង្ឃខ្មែរ និងបរទេសខ្លះផង ធ្វើឱ្យភិក្ខុសង្ឃ និងពុទ្ធសាសនានៅកម្ពុជា មានកិត្តិស័ព្ទល្បីខ្ចរខ្ចារ តាមរយៈស្នាដៃជាច្រើន មានស្នាដៃបកប្រែគម្ពីរព្រះត្រៃបិដកពីភាសាបាលី មកជាភាសាខ្មែរជាដើម ដែលការងារនេះ គឺជាស្នាដៃដំបូងគេបង្អស់ក្នុងចំណោមប្រទេសកាន់ព្រះពុទ្ធសាសនាក្នុងលោក ហើយជាស្នាដៃមានតម្លៃខ្ពស់ត្រូវប្រើពេលអស់៤០ឆ្នាំ ទើបសំរេចបានចប់សព្វគ្រប់ ។

ប៉ុន្តែព្យុះនយោបាយដ៏លិចលង់មួយ ដែលបានបក់បោកលើប្រទេសយើង ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ បានវាយកំទេចស្ថាប័នជាតិ ដែលមានមកពីមុនទាំងអស់ ដោយរួមទាំងពុទ្ធសាសនបណ្ឌិត្យផង

ឱ្យរលំរលាយគ្មានសេសសល់ ។ ចាប់ពីដើមឆ្នាំ១៩៧៩ រៀងមក, ស្ថាប័នជាតិទាំងឡាយក៏បានកើតមានឡើយវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់ ។ នៅដើមឆ្នាំ១៩៩២ ក្រសួងធម្មការ ត្រូវបានបង្កើតឡើងវិញ ។ ចាប់ពីពេលនោះមក ស្ថាប័នទាំងអស់ ដែលធ្លាប់នៅក្រោមឱវាទក្រសួងធម្មការ តាមទម្លាប់ពីមុនក៏ត្រូវបានផ្ទេរមកឱ្យក្រសួងធម្មការគ្រប់គ្រងឡើងវិញ ដូចជា ពុទ្ធសាសនបណ្ឌិត្យ, ការគ្រប់គ្រងពុទ្ធិកសិក្សា, ការគ្រប់គ្រងវត្តអារាម និងការគ្រប់គ្រងសាសនា ដែលពីមុននេះឋិតក្រោមឱវាទក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី កសាងការពារមាតុភូមិកម្ពុជា ។ ដោយឡែក ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៩២ រៀងមក, ពុទ្ធសាសនបណ្ឌិត្យ ដែលបានជ្រកនៅក្នុងវត្តឧណ្ណាលោមជាបណ្តោះអាសន្ននោះ បានធ្វើដំណើរលើមាគ៌ារីកចំរើនប្រកបដោយជោគជ័យ ដោយបានទទួលការឧបត្ថម្ភ ពីអង្គការសាសនាពីប្រទេសជប៉ុន តាមរយៈ អង្គការជំនួយសូតូស៊ូជប៉ុននៅកម្ពុជា ហើយនិងពីមូលនិធិហ៊ានរីសបូលនៃប្រទេសអាល្លឺម៉ង់ ។

អាគារដ៏ត្រដុងត្រដោមស្កឹមស្កៃ នៅចំពោះមុខយើងនេះ គឺជាអំណោយកាត់ថ្លៃពុំបានរបស់អង្គការសាសនា វិស្សូកូសី-កៃ ពីប្រទេសជប៉ុន និងជានិមិត្តរូបនៃការប្រកាសបើកសករាជថ្មីឆ្ពោះទៅកាន់ការអភិវឌ្ឍន៍បញ្ញាស្មារតី ក្រោមពន្លឺនៃព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ និងឆ្ពោះទៅកាន់សុខសន្តិភាពក្នុងចិត្តក្នុងកាយជានិរន្តន៍សម្រាប់ប្រជារាស្ត្រ និងប្រទេសកម្ពុជាទាំងមូល ។ ព្រះសង្ឃ និងពុទ្ធសាសនិកជនខ្មែរគ្រប់រូបមានជំនឿយ៉ាងមុតមាំថា ផ្សាយចេញពីអាគារដ៏ស្កឹមស្កៃនេះទៅ ខ្លឹមសារនៃព្រះធម៌ប្រកបដោយមេត្តាករុណា មុទិតា ឧបេក្ខា និងសន្តិភាព នឹងគ្របដណ្តប់ទៅលើផ្ទៃប្រទេសកម្ពុជាទាំងមូលធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានចិត្តគំនិតយោគយល់គ្នា, សន្តោសគ្នា អធ្យាស្រ័យដល់គ្នាទៅវិញទៅមកក្រោមម្លប់នៃព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ បរមគ្រូ តរៀងទៅ ។

អំណោយអគារដ៏វិសេសវិសាលរបស់អង្គការវិស្សូកូស៊ុ-កៃនៃប្រទេសជប៉ុន ឧទ្ទិសចំពោះពុទ្ធសាសនបណ្ឌិត្យ មានតម្លៃខ្ពស់ជាអនេក ពុំមែនគ្រាន់តែ ដើម្បីជួយស្តារឡើងវិញនូវកិត្តិយសតួនាទី និងសកម្មភាពការងារជាកុសលរបស់ពុទ្ធសាសនបណ្ឌិត្យ ដែលបាត់ទៅប៉ុណ្ណោះទេ, ប៉ុន្តែអំណោយអគារនេះបានឆ្លុះបញ្ចាំង ឱ្យឃើញនូវទឹកចិត្តស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ និងស្មោះសររបស់ពុទ្ធសាសនិកជនជប៉ុន និកាយវិស្សូ កូសី-កៃ ចំពោះពុទ្ធសាសនិកជនកម្ពុជា និកាយ ថេរវាទ ដែលជួបលំបាក ហើយក្រខ្សត់ ។ អំណោយអគារនេះនឹងត្រូវបានប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ចាត់ទុកជាចំណងតភ្ជាប់យ៉ាងជិតស្និទ្ធនៃភាតរភាព និងមិត្តភាពជាអមតៈរវាងប្រជារាស្ត្រ និងប្រទេស

ទាំងពីរគឺកម្ពុជា-ជប៉ុន ។

អគារដ៏ល្អប្រកបដោយ រចនាបថវប្បធម៌ថ្មីនេះ នឹងត្រូវបានប្រើប្រាស់ជាមណ្ឌលសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយពុទ្ធសាសនា និងវប្បធម៌-អរិយធម៌សាសនា ព្រមទាំងប្រពៃណីទំនៀមទំលាប់ជាតិ ដើម្បីជាគុណប្រយោជន៍ស្តារឡើងវិញនូវសីលធម៌-អភិសមាចារសង្គមនៃប្រជាជាតិមួយដូចជាប្រទេសកម្ពុជានេះ ដែលធ្លាប់មានអតីតកាលដ៏រុងរឿង, ធ្លាប់មានអរិយធម៌ចិញ្ចែចចិញ្ចែង ហើយបានធ្លាក់ផុងយ៉ាងជ្រៅក្នុងអន្លង់នៃសង្គ្រាម និងការបែកបាក់សាមគ្គីភាព ក្នុងប៉ុន្មានសតវត្សកន្លងមកនេះ ។ ខ្ញុំព្រះករុណាខ្ញុំមានជំនឿថា អគារដ៏ល្អថ្មីនេះ នឹងបានជាវិភាគទានមួយ ជួយអ្នកសិក្សា,ស្រាវជ្រាវ របស់យើងឱ្យរកឃើញនូវទស្សនៈថ្មី គំនិតយល់ដឹងថ្មី និងបែបបទគិតគូរថ្មី ដែលនឹងនាំប្រជាជាតិកម្ពុជា ឆ្ពោះទៅកាន់សុខសន្តិភាព ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍន៍ជាប់លាប់យូរអង្វែង ប្រកបដោយប្រជាធិបតេយ្យសេរីភាព សមភាពពិតប្រាកដ ។

នៅក្នុងស្មារតីនេះ ខ្ញុំព្រះករុណាខ្ញុំ យល់ថាតួនាទីរបស់ព្រះពុទ្ធសាសនា នៅក្នុងសង្គមកម្ពុជាមានសារៈសំខាន់ពេកណាស់ ដែលត្រូវបន្តយកចិត្តទុកដាក់ឱ្យបានសមស្របទៅនឹងឋានៈ ផ្តល់ជូនព្រះពុទ្ធសាសនា នៅក្នុងច្បាប់កំពូលរបស់ប្រទេស គឺរដ្ឋធម្មនុញ្ញដែលចែងថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ស្របទៅនឹងឋានៈនេះរបស់ព្រះពុទ្ធសាសនា, ពុទ្ធសាសនបណ្ឌិត្យ ដែលជាស្ថាប័នរបស់ជាតិតែមួយគត់ នៅក្នុងអាយុកាលជាងកន្លះសតវត្សរបស់ខ្លួនកន្លងទៅនេះ ត្រូវបន្តការសិក្សាស្រាវជ្រាវបោះពុម្ពផ្សាយខ្លឹមសារនៃព្រះធម៌, ព្រមទាំងអក្សរសាស្ត្រ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ជាតិជាបន្តទៀត ដើម្បីលើកកំពស់មនសិការសង្គម និងដុះខាត់បញ្ញាស្មារតីប្រជាពលរដ្ឋឱ្យបានភ្លឺថ្លាឡើងវិញ ។ ពុទ្ធសាសនបណ្ឌិត្យត្រូវបានមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ទទួលស្គាល់ជាទូទៅថា ជាមជ្ឈមណ្ឌលសិក្សា-ស្រាវជ្រាវ និងជាមជ្ឈមណ្ឌលឯកសារ សមោធានមួយដ៏សំខាន់របស់ប្រទេស ជាពិសេសឯកសារទាក់ទងនឹងវប្បធម៌អរិយធម៌បូព៌ាប្រទេស ។

ប្រការពិសេសមួយទៀត, ពុទ្ធសាសនបណ្ឌិត្យ នៅក្នុងអតីតកាល ក៏ដូចក្នុងពេលបច្ចុប្បន្ន គឺជាស្ថាប័នដ៏សំខាន់មួយ ដែលរួមចំណែកជួយពុទ្ធិកសិក្សា ធ្វើឱ្យព្រះភិក្ខុសង្ឃរបស់យើងមានកិត្តិនាមល្បីល្បាញជាពហុស្សូត ហើយសង្គមជាតិរបស់យើងក៏មានកេរ្តិ៍ឈ្មោះពិរោះពិសារ ដោយសារមានសីលធម៌ល្អ, មានអភិសមាចារខ្ពស់ហើយប្រជាជនរស់នៅថ្លៃថ្នូរ ។ អាស្រ័យហេតុនេះ ការយកចិត្តទុកដាក់ធ្វើឱ្យ

ពុទ្ធសាសនបណ្ឌិត្យ មានសមត្ថភាព និងលទ្ធភាពសមស្រប ដើម្បីបំពេញបេសកកម្មលើកស្ទួយ និងផ្សព្វ-ផ្សាយតម្លៃ ព្រះធម៌ ក៏ដូចជាលើកស្ទួយសីលធម៌ និងអភិសមាចារសង្គមឡើងវិញ គឺជាកាតព្វកិច្ចចាំបាច់ ក្នុងពេលដែលតម្លៃ សីលធម៌ និងអភិសមាចារសង្គមបច្ចុប្បន្នកំពុងធ្លាក់ចុះគួរឱ្យព្រួយបារម្ភបំផុត ។

- បពិត្រសម្តេច និងព្រះមហាថេរានុត្ថេរ ជាទីសក្ការៈ
- ព្រះតេជគុណប្រធាន និងសមាជិកគណៈប្រតិភូវិស្សូ កូសី-កែ និងសមាគមស្ម័គ្រចិត្ត សូតូស៊ូ ជាទីគោរព
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បងប្អូន ជនរួមជាតិជាទីមេត្រី

ដោយពិធីសម្ពោធនាថ្ងៃនេះ ស្ថិតនៅក្នុងរយៈពេលសប្តាហ៍ទី២ នៃការចុះឈ្មោះបោះឆ្នោត ដែលប្រជារាស្ត្រយើងទូទាំងប្រទេសកំពុងចូលរួមយ៉ាងសកម្មនោះ ខ្ញុំព្រះករុណាខ្ញុំ សូមឆ្លៀតឱកាសនេះសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ជូនប្រទេសនានាជាមិត្ត-ជិតឆ្ងាយ និងសហគមន៍អន្តរជាតិ ដែលបានជួយឧបត្ថម្ភគាំទ្រ ទាំងសម្ភារៈ ថវិកា ទាំងធនធានមនុស្ស ដើម្បីជួយឱ្យដំណើរការបោះឆ្នោតនៅកម្ពុជានាពេលខាងមុខ បានប្រព្រឹត្តទៅទាន់ពេលវេលា ត្រឹមត្រូវ និងយុត្តិធម៌ ។

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវការកោតសរសើរដ៏ខ្ពង់ខ្ពស់ ជូនរដ្ឋសភា រាជរដ្ឋាភិបាល គណកម្មា-ធិការជាតិរៀបចំបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ដែលបានបញ្ចេញកំឡាំងខិតខំប្រឹងប្រែងទាំងអស់គ្នា ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់នៃការបោះឆ្នោត និងបានម្ចាស់ការលះបង់ធ្វើអ្វីៗគ្រប់បែបយ៉ាង សំដៅធ្វើឱ្យការបោះឆ្នោតអាចប្រព្រឹត្តទៅបានដោយសុខសាន្ត គ្មានការបំភិតភ័យ បង្ខិតបង្ខំ និងអំពើហឹង្សា ដោយមានយន្តការរៀបចំ អព្យាក្រឹត ដែលប្រកាន់ច្បាប់ និងការបំរើរាស្ត្រម្ចាស់ឆ្នោតជាធំ ហើយស្មោះស្ម័គ្រដើរតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ។

ខ្ញុំព្រះករុណាខ្ញុំ ក៏សូមឆ្លៀតឱកាសនេះផងដែរ ដើម្បីអំពាវនាវដល់រាជរដ្ឋាភិបាល កងកំលាំងប្រដាប់អាវុធ និងអាជ្ញាធរជាតិគ្រប់ជាន់ថ្នាក់ សូមមេត្តាលើកកំពស់ស្មារតីប្រុងប្រយ័ត្ន ស្មារតីការពារសន្តិ - សុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឱ្យបានកាន់តែខ្ពង់ខ្ពស់ឡើងថែមទៀត ដើម្បីធ្វើឱ្យបរិយា - កាស និងដំណើរការបោះឆ្នោត ប្រព្រឹត្តទៅបានដោយសុខដុមរម្យនា ដោយទប់ស្កាត់បាននូវអំពើអសកម្ម ផ្សេងៗ ជាអាទិ៍ អំពើអានាធិបតេយ្យ អំពើក្បៀបសង្កត់ ការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហឹង្សាផ្សេងៗ ដែលអាចឆក់ឱកាសកើតឡើងបាន បណ្តាលមកពីពួកឱកាសនិយម ។

ដោយយុទ្ធនាការឃោសនាបោះឆ្នោត និងពេលបោះឆ្នោត នឹងឈានមកដល់ជាបន្តបន្ទាប់នាពេលខាងមុខ ខ្ញុំព្រះករុណាខ្ញុំ សូមធ្វើការអំពាវនាវជាថ្មីទៅកាន់គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ក៏ដូចជាបងប្អូនជនរួមជាតិទាំងអស់ដែរ សូមគោរពដោយខ្ជាប់ខ្ជួន តាមវិធាន បទបញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជា និងនីតិវិធី របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយសូមគោរពតាមគោលការណ៍ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយើង ។ មានតែធ្វើបែបនេះទេ ទើបការបោះឆ្នោតនាពេលខាងមុខប្រព្រឹត្តទៅ ដោយជោគជ័យក្នុងស្មារតីសាមគ្គីភាព ឯកភាពជាតិល្អប្រពៃ ដែលអាចប្រមូលផ្តុំកំលាំងជាតិទាំងមូល ឆ្ពោះទៅការអភិវឌ្ឍន៍ សន្តិភាព និងការបង្រួបបង្រួមផ្សះផ្សាជាតិពិតប្រាកដ ដែលជាបំណងប្រាថ្នារួមរបស់ប្រជារាស្ត្រយើងផង និងសហគមន៍អន្តរជាតិផង ។

ប្រជាពលរដ្ឋម្នាក់ៗ ទោះជាស្រឡាញ់គាំទ្រគណបក្សណាក៏ដោយ សូមមេត្តាបង្ហាញនូវសេចក្តីថ្លៃថ្នូរ យកធម៌ព្រះពុទ្ធធ្វើជាឱសថរំងាប់ ទោសៈ មោហៈ លោភៈ និងការច្រណែនឈ្នានិះ ចងអាឃាតគ្នា ហើយចៀសវាងការធ្វើសកម្មភាពណាមួយនាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ពលរដ្ឋដទៃ ដែលចង់សំដែងឆន្ទៈពិតរបស់ខ្លួន ក្នុងការជ្រើសរើសខាងនយោបាយតាមរយៈសន្លឹកឆ្នោត ។

ក្នុងនាមប្រជារាស្ត្រទូទាំងប្រទេស ក្នុងនាមរដ្ឋសភា និងក្នុងនាមរាជរដ្ឋាភិបាល, ខ្ញុំព្រះករុណាខ្ញុំ សូមលំឱនកាយថ្វាយព្រះពរ បវរមហាប្រសើរ ដែលកើតពីបុញ្ញកម្មនាឱកាសនេះ ថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ, សូមព្រះអង្គបានប្រកបដោយព្រះបរមសុខក្នុងព្រះសិរីរាជសម្បត្តិ មានព្រះជន្មាយុយឺនយូរ ទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ កូន ចៅ ចៅទួតរបស់ព្រះអង្គ អស់កាលជាអង្វែងតទៅ ។

ខ្ញុំព្រះករុណាខ្ញុំ សូមប្រសិទ្ធិពរ បវរមហាប្រសើរ ថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជូនឯកឧត្តម លោកជំទាវ លោកស្រី នាងកញ្ញា អស់លោក ភ្ញៀវ កិត្តិយសជាតិ-អន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយព្រះពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ។

ជាពិសេស ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមប្រជារាស្ត្រទាំងព្រះសង្ឃទាំងគ្រហស្ថ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនផ្ទាល់ សូមអរគុណអង្គការវិស្សូ កូស៊ី-កៃ យ៉ាងជ្រាលជ្រៅបំផុត ចំពោះអំណោយដ៏សប្បុរសជាអគារដ៏ល្អ ប្រកបដោយរចនាបថថ្មីស្រឡាង សម្រាប់ធ្វើជាទីតាំងរបស់ពុទ្ធសាសនបណ្ឌិត្យ និងសូមអរគុណសមាគមស្ម័គ្រចិត្ត សូតូស៊ូ ប្រចាំនៅកម្ពុជា ដែលបានទទួលបន្ទុកគ្រប់គ្រងការសាងសង់អគាររហូតដល់បានសំរេចជាស្ថាពរ ។ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពុទ្ធពរបវរមហាប្រសើរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ ចំពោះព្រះតេជព្រះគុណប្រធាន និងសមាជិកគណៈប្រតិភូ វិស្សូ កូសី-កៃ និងព្រះតេជគុណប្រធានសមាគមស្ម័គ្រចិត្តសូតូស៊ូ មួយអន្លើដោយបរិស័ទនៃអង្គការទាំងពីរ សូមបានសំរេចបរមសុខ គឺព្រះនិញ្វន កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឱ្យសាមគ្គីភាព ភាតរភាព រវាងពុទ្ធសាសនិកជនកម្ពុជា-ជប៉ុន ឋិតថេរជាអមតៈ !

<u>សូមអរព្រះគុណ - អរគុណ</u>